ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...៥៤១៧...អពដ

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៦ និងការអនុគ្រោះលើកលែងទោសទណ្ឌនានាក្នុងការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត និងការផ្តល់របាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំ២០១៦

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់ឲ្យបានជ្រាបថា កន្លងមកអគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា ការកាន់កាប់បញ្ជិកាគណនេយ្យនិងដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់សហគ្រាសមួយចំនួនបានត្រឹមត្រូវ និងមួយចំនួនទៀតបានស្នើសុំកែតម្រូវបញ្ជិកាគណនេយ្យនិងប្រាក់បង់ប្រាក់ពន្ធឡើងវិញជាបន្តបន្ទាប់ដោយស្របតាមសេចក្តីជូនដំណឹងលេខ១២១៩ អពដ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការអនុគ្រោះលើកលែងទោសទណ្ឌនានាក្នុងការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត។ សហគ្រាសមួយចំនួនបានស្នើសុំការកែតម្រូវបញ្ជិកាគណនេយ្យមានរយៈពេលច្រើនឆ្នាំជាប់ៗគ្នា បណ្តាលឲ្យមានការយឺតយ៉ាវក្នុងការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ២០១៦ផងដែរ ហើយសហគ្រាសមួយចំនួនក៏បានដាក់លិខិតមកស្នើសុំពន្យារពេលការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៦។ ជាមួយគ្នានេះដែរមានសហគ្រាសមួយចំនួនបានស្នើសុំពន្យារពេលការផ្តល់របាយការណ៍សវនកម្មឯករាជ្យ ដោយមូលហេតុការធ្វើសវនកម្មដោយក្រុមហ៊ុនគណនេយ្យនិងសវនកម្មជំនាញមិនទាន់ត្រូវបានបញ្ចប់នៅឡើយ។

ដើម្បីដោះស្រាយបញ្ហានេះ អគ្គនាយកដ្ឋានពន្ធដារ សម្រេចដូចខាងក្រោម ÷

១- ការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៦ ត្រូវពន្យារពេលរហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧

២- ការអនុគ្រោះលើកលែងទោសទណ្ឌនានាក្នុងការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្តយ៉ាងតិច ៣ឆ្នាំ ត្រូវពន្យារពេលរហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧

៣- ការផ្តល់របាយការណ៍សវនកម្មឯករាជ្យ ត្រូវពន្យារពេលរហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា ការពន្យារកាលបរិច្ឆេទខាងលើនេះ នឹងជួយសម្រួលដល់លោក/លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន។ ក្នុងករណីហួសកាលកំណត់នេះ សហគ្រាសលោក/លោកស្រី ត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធ។

Collection by VCAT Professional Consultant

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល